# ស្រុក_____________ (ក្រុង)________

# លិខិតស្ម័គ្រចិត្ត និងសេចក្តីជូនដំណឹងព្រមនឹងការពន្យល់នៃការចាក់វ៉ាក់សាំងបង្ការជម្ងឺគ្រុនផ្តាសាយ

ឪពុកម្តាយសិស្សជាទីគោរព៖

សាលាយើងខ្ញុំនឹងសហការជាមួយនឹងក្រុមវេជ្ជសាស្រ្តចុះកិច្ចសន្យាជាមួយមន្ទីរសុខាភិបាលខេត្ត(ក្រុង)យើង ក្រុមវិជ្ជបណ្ឌិតផ្តល់ការចាក់វ៉ាក់សាំងបង្ការជម្ងឺគ្រុនផ្តាសាយសម្រាប់កូនរបស់លោកអ្នកនៅថ្ងៃ ___ ខែ_____ឆ្នាំ២០២៣។ ជាពិសេសសាលាយើងខ្ញុំសូមជូនដំណឹងហើយស្នើសុំការយល់ព្រមរបស់លោកអ្នក សូមអានព័ត៌មានខាងក្រោមរួចហើយសរសេរបំពេញលិខិតស្ម័គ្រចិត្តចាក់វ៉ាក់សាំងបន្ទាប់មកឱ្យកូននាំយកទៅប្រគល់ជូនសាលាវិញ សូមអរគុណចំពោះការគាំទ្រនិងសហការរបស់លោកអ្នក!

------------------------------------------------------------------------------------------------------------

《តើអ្វីទៅហៅថាជម្ងឺគ្រុនផ្តាសាយ》

ជម្ងឺគ្រុនផ្តាសាយជាជម្ងឺកើតមកពី [ដោយវីរុសគគ្រុនផ្តាសាយ] នាំឲ្យមានក្នុងផ្លូវដង្ហើមធ្ងន់ធ្ងរដែលបណ្តាលមកពីវាមានភាពខុសពីជម្ងឺផ្តាសាយធម្មតា តាមធម្មតាមានរោគសញ្ញាច្បាស់ជាង ហើយអំឡុងពេលក៏យូរវែងជាង។ រោគសញ្ញាទូទៅរួមមានដូចជា គ្រុនក្តៅ ឈឺក្បាល ឈឺសាច់ដុំ នឿយហត់ ហៀរសំបោរ ឈឺបំពង់ក និងក្អកជាដើម ជួនកាលនឹងបណ្តាលឱ្យហកជម្ងឺនឹងអាចបណ្តាលឱ្យស្លាប់។ ហកជម្ងឺដែលធ្លាប់ជួបដូចជាជម្ងឺរលាកសួត ជម្ងឺផ្សេងទៀតដូចជារលាកត្រចៀកកណ្តាល ជម្ងឺរលាករន្ធច្រមុះ រលាកខួរក្បាល ជម្ងឺខួរក្បាល រលាកទងបេះដូង រោគសញ្ញានឹងពន្លឺរស្មីនិងជម្ងឺរ៉េនិងជម្ងឺឆ្លងធ្ងន់ធ្ងរផ្សេងៗទៀត។

《តើជម្ងឺគ្រុនផ្តាសាយឆ្លងតាមរបៀបអ្វី》

ជម្ងឺគ្រុនផ្តាសាយបណ្តាលមកពីក្អកកណ្តាស់មានវីរុសឆ្លងមេរោគដល់មនុស្សជុំវិញ ហើយក៏មានលទ្ធភាពឆ្លងតាមរយៈការប៉ះមាត់និងច្រមុះរបស់ខ្លួនបន្ទាប់ពីបានប៉ះពាល់នឹងមេរោគគ្រុនផ្តាសាយនៅលើផ្ទៃនៃវត្ថុដែលមានផ្ទុកវីរុស។ មុនពេល1ថ្ងៃនឹងកើតជម្ងឺ ឬក្រោយពេលកើតជម្ងឺ៣-៧ថ្ងៃ អ្នកមានជម្ងឺគ្រុនផ្តាសាយក៏មានលទ្ធភាពឆ្លងជម្ងឺដល់អ្នកផ្សេងទៀត ចំពោះក្មេងៗ អំឡុងឆ្លងជម្ងឺកាន់តែយូរ។

《សារៈសំខាន់នៃការចាក់វ៉ាក់សាំងបង្ការជម្ងឺគ្រុនផ្តាសាយសំរាប់សិស្ស》

យោងតាមការសិក្សាស្រាវជ្រាវបានរកឃើញថា សិស្សានុសិស្សងាយឆ្លងមេរោគគ្រុនផ្តាសាយណាស់ ជាទូទៅ សិស្សជាអ្នកកើតជម្ងឺមុនគេនៅរដូវឆ្លងជម្ងឺ ម្យ៉ាងទៀតមេរោគដែលរាលដាលដោយសិស្សមានកម្លាំងឆ្លងខ្ពស់ជាង ហើយពេលឆ្លងយូរជាង ដូច្នេះ សិស្សទាំងឡាយគឺជាអ្នករាលដាលមេរោគគ្រុនផ្តាសាយសំខាន់ៗ។ ការចាក់វ៉ាក់សាំងជម្ងឺគ្រុនផ្តាសាយសំរាប់សិស្ស មិនត្រឹមតែមានប្រសិទ្ធភាពកាត់បន្ថយអត្រាឆ្លងជម្ងឺគ្រុនផ្តាសាយរបស់សិស្ស បន្ថយការចំណាយលើថ្លៃពេទ្យ ថែមទាំងអាចកាត់បន្ថយការរាលដាលនៃវីរុស ហើយការពារក្រុមមានគ្រោះថ្នាក់ដោយប្រយោល ដូចជាចាស់និងក្មេងៗ ដើម្បីកាត់បន្ថយផលវិបាកយ៉ាងធ្ងន់ធ្ងរដែល បណ្តាលមកពីគេឆ្លងជម្ងឺ។

《សមាសធាតុនៃវ៉ាក់សាំងបង្ការជម្ងឺគ្រុនផ្តាសាយក្នុងឆ្នាំនេះ》

វ៉ាក់សាំងបង្ការជម្ងឺគ្រុនផ្តាសាយជាវ៉ាក់សាំងអសកម្មមួយប្រភេទ តាមសំណើរបស់អង្គការសុខភាពពិភពលោក រដ្ឋាភិបាលបានទិញវ៉ាក់សាំង៤ប្រភេទដូចជាបណ្តាប្រទេសលើសកលលោក ក្នុងវ៉ាក់សាំងនេះមានធាតុផ្សំវីរុសអសមក្ម ៤ ប្រភេទ គឺប្រភេទ A ២មុខ(H1N1 និង H3N2) និងប្រភេទB ១មុខ។ សមាសធាតុ

នៃវ៉ាក់សាំងនីមួយៗបណ្តុះបណ្តាលដោយស៊ុតអំប្រ៊ីយ៉ុងមាន់ដែលប្រើប្រាស់នៅឆ្នាំ(<u>២០២៣</u>)នេះមាន៖ A/Victoria/4897/2022 (H1N1)pdm09-like virus； A/Darwin/9/2021 (H3N2)-like virus；B/Austria/1359417/2021 (B/Victoria lineage)-like virus；B/Phuket/3073/2013 (B/Yamagata lineage)-like virus ។ សមាសធាតុនៃវ៉ាក់សាំងនីមួយៗដែលបណ្តុះបណ្តាលដោយកោសិកាមាន៖A/Wisconsin/67/2022 (H1N1)pdm09-like virus；A/Darwin/6/2021 (H3N2)-like virus； B/Austria/1359417/2021 (B/Victoria lineage)-like virus；B/Phuket/3073/2013 (B/Yamagata lineage)-like virus។

《បរិមាណចាក់វ៉ាក់សាំង រយៈពេលចាក់វ៉ាក់សាំងនិងរបៀបបង់ថ្លៃ》

ចំពោះសិស្ស ត្រូវចាក់វ៉ាក់សាំង0,៥មីលីលីត្រក្នុងម្តង។ ម្យ៉ាងទៀត ចំពោះកុមារមានអាយុតិចជាង(ស្មើនឹង) ៩ឆ្នាំ ប្រសិនចាក់វ៉ាក់សាំងជាលើកដំបូង គួរតែចាក់ ២ដូស និង ការចាក់២ដូសនេះ ត្រូវចាំរយៈពេលជាង ៤សប្តាហ៍ រួចចាក់ បើសិនធ្លាប់ចាក់វ៉ាក់សាំងបង្ការជម្ងឺគ្រុនផ្តាសាយ(មិនថា១ដូសឬ២ដូស) នៅឆ្នាំនេះចាក់១ដូសក៏បាន។ ចំពោះកុមារមានអាយុលើសពី៩ឆ្នាំ មិនថាកន្លងមកធ្លាប់ចាក់វ៉ាក់សាំងឬទេ សុទ្ធតែត្រូវចាក់១ដូសប៉ុណ្ណោះ។ ដោយសារវីរុសគ្រុនផ្តាសាយរាល់ ឆ្នាំមិនដូចគ្នាទេ ដូច្នេះ អ្នកពេញលក្ខណៈចាក់វ៉ាក់សាំង ត្រូវតែចាក់វ៉ាក់សាំងជាថ្មី

រៀងរាល់ឆ្នាំ។ ក្រោយពីចាក់វ៉ាក់សាំងរួច យ៉ាងហោចណាស់រងចាំប្រហែល២ សប្តាហ៍ទើបមានសក្តិសិទ្ធិការពារ ហើយឥទ្ធិពលការពារមានរយៈពេលក្នុង១ឆ្នាំ។

យើងអាចចាក់វ៉ាក់សាំងបង្ការជម្ងឺគ្រុនផ្តាសាយជាមួយវ៉ាក់សាំងផ្សេងទៀតក្នុងពេលជាមួយគ្នា នៅចំណែកខុសពីគ្នាលើដងខ្លួន ឬចាក់វ៉ាក់សាំងរងចាំចន្លោះពេលខ្លះ។ វ៉ាក់សាំងដែលផ្តល់ក្នុងឆ្នាំនេះផលិតឬនាំចូលដោយក្រុមហ៊ុន Adimmune Corporation តៃវ៉ាន់ ក្រុមហ៊ុនSanofi Taiwan Co., Ltd បារាំង ក្រុមហ៊ុនTTY Biopharm Company Limited តៃវ៉ាន់និងក្រុមហ៊ុនMedigen Vaccine Biologics Corporation , MVC វ៉ាក់សាំងដែលផលិតដោយក្រុមហ៊ុនទាំង៤នេះមានប្រសិទ្ធិភាពនិងសុវត្ថិភាពតាមកំណត់ចុះបញ្ជីត្រួតពិនិត្យនៃនាយកដ្ឋានគ្រប់គ្រងអាហារនិងថ្នាំនៃក្រសួងសុខាភិបាលនិងសុខុមាលភាពអានាម័យតំបន់តៃវ៉ាន់ ហើយត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់/នាំចូល នឹងផ្គត់ផ្គង់តាមលំដាប់ដែលវ៉ាក់សាំងត្រូវជញ្ជូនដល់ឃ្លាំង។ ពេលចាក់វ៉ាក់សាំងសំរាប់សិស្សទាំងឡាយក្នុងសាលាជាសមូហភាព នឹងចាក់វ៉ាក់សាំង១ដូសដោយប្រើប្រាក់រដ្ឋ ហើយមិនបាច់ចំណាយប្រាក់អ្វីទេ ប៉ុន្តែចំពោះអ្នកណាមិនអាចទទួលការចាក់វ៉ាក់សាំងនៅថ្ងៃបានកំណត់ នោះត្រូវយកលិខិតជូនដំណឹងផ្តល់ដោយសាលា ទៅមន្ទីរពេទ្យចាក់វ៉ាក់សាំង ហើយបង់ថ្លៃព្យាបាលពាក់ព័ន្ធ។ ក្នុងករណីជាសិស្សចូលបឋមសិក្សាក្រោមថ្នាក់ទី២ ហើយចាក់វ៉ាក់សាំងលើកដំបូងក្រោយពីកើតមក បើសិនចង់ ម្តងទៀត អាចទៅមន្ទីរពេទ្យចាក់ហើយត្រូវបង់បង់ថ្លៃដោយខ្លួនឯង ចាក់ដូសទី២បន្ទាប់ពីចាក់វ៉ាក់សាំងដូសទី១ នៅសាលាយ៉ាងហោចណាស់៤ សប្តាហ៍។

《សក្តិសិទ្ធិការពារនៃវ៉ាក់សាំង》

សក្តិសិទ្ធិការពារនៃវ៉ាក់សាំងបង្ការជម្ងឺគ្រុនផ្តាសាយប្រែប្រួលតាមអាយុឬស្ថានភាពរាងកាយ អត្រាសក្តិសិទ្ធិគឺ30-80%ជាមធ្យម ចំពោះមនុស្សពេញវ័យលើសពី18ឆ្នាំ បានឆ្លងជម្ងឺគ្រុនផ្តាសាយហើយស្នាក់នៅមន្ទីរពេទ្យ មានសក្តិសិទ្ធិការពារប្រហែល41% ចំពោះមនុស្សឆ្លងជម្ងឺគ្រុនផ្តាសាយធ្ងន់ធ្ងរ បានស្នាក់នៅបន្ទប់ថែទាំជាពិសេស មានសក្តិសិទ្ធិការពារដល់ 82%។ ក្មេងៗមានអាយុលើសពី 6ខែដល់យុវជនមានអាយុតិចជាង18ឆ្នាំ ក្រោយពីចាក់វ៉ាក់សាំងបង្ការជម្ងឺគ្រុនផ្តាសាយ មានសក្តិសិទ្ធិការពារស្មើនឹងមនុស្សពេញវ័យ។

《តំណមនៅពេលទទួលវ៉ាក់សាំង》

I. ចំពោះអ្នកណាបានដឹងថាមានប្រតិកម្មទៅនឹងសមាសធាតុនៃវ៉ាក់សាំង នោះមិនត្រូវចាក់វ៉ាក់សាំងទេ។

II. ចំពោះអ្នកណាមានប្រតិកម្មអាក្រកធ្ងន់ធ្ងរ នៅពេលចាក់វ៉ាក់សាំងកាលពីមុន នោះមិនត្រូវចាក់វ៉ាក់សាំងទេ។

《កំណត់សំគាល់នៅពេលទទួលវ៉ាក់សាំង》

I. អ្នកជម្ងឺក្តៅខ្លួន ឬកំពុងមានជម្ងឺធុនមធ្យម ធុនធ្ងន់ជាបន្ទាន់ គួររងចាំជម្ងឺជាសៀយសិន រួចចាក់វ៉ាក់សាំងល្អជាង។

II. ទារកមិនទាន់គ្រប់៦ខែ ដោយសារគ្មានឯកសារអំពីឥទ្ធិពលចាក់វ៉ាក់សាំងនិងសុវត្ថិភាពនៅមន្ទីរពេទ្យ ដូច្នេះ មិនត្រូវចាក់វ៉ាក់សាំងទេ។

III. អ្នកណាកើតរោគសញ្ញាGuillain-Barré(GBS)ក្រោយពីចាក់វ៉ាក់សាំងនេះក្នុងអំឡុងពេល៦អាទិត្យ សូមរកគ្រូពេទ្យវាយតម្លៃសិន។

IV. អ្នកណាមានប្រតិកម្មចំពោះប្រូតេអ៊ីនក្នុងស៊ុតអាចចាក់វ៉ាក់សាំងដោយបុគ្គលិកពេទ្យដែលពេញលក្ខណៈសម្បត្តិ ហើយធ្លាប់ដោះស្រាយរោគសញ្ញាប្រតិកម្មក្រោយពីចាក់វ៉ាក់សាំង ត្រូវអង្កេតមើលក្នុងរយៈពេល៣០នាទីរងចាំគ្មានរោគសញ្ញាមិនស្រួល ទើបអាចចេញទៅ។

V. អ្នកដទៃទៀតដែលគ្រូពេទ្យវាយតម្លៃថា មិនគួរចាក់វ៉ាក់សាំង គឺមិនត្រូវចាក់វ៉ាក់សាំងទេ។

《ប្រតិកម្មសន្លប់ពេលចាក់ម្ជុលជាទូទៅពេលកុមារទទួលវ៉ាក់សាំង》

ការសន្លប់ពេលចាក់ម្ជុលតែងតែបណ្តាលមកពីសម្ពាធ និងអារម្មណ៍ភិតភ័យក្នុងចិត្តចំពោះការចាក់ម្ជុល ហើយក្លាយទៅជារោគសញ្ញារាងកាយ ដូចជាវិលមុខនិងចង្អោរ ភាគច្រើនកើតនៅពេលមានកុមារជាច្រើនទទួលចាក់វ៉ាក់សាំងជាមួយគ្នា។ នៅពេលចាក់វ៉ាក់សាំងសំរាប់មនុស្សជាច្រើន ជួនកាលនឹងកើតបាតុភូតដែលមានមនុស្សសន្លប់ជាច្រើន នេះហៅថារោគផ្លូវចិត្តជាសមូហភាព។ ប្រតិកម្មសន្លប់ពេលចាក់ម្ជុលគ្មានទំនាក់ទំនងជាមួយនឹងសុវត្ថិភាពវ៉ាក់សាំងទេ ហើយមិនដែលបង្កជម្ងឺបន្សល់អ្វីចំពោះសុខភាពរាងកាយទេ។

យើងស្នើថា មុននឹងចាក់វ៉ាក់សាំង អ្នកទទួលចាក់វ៉ាក់សាំងកុំទុកពោះឃ្លានយូរពេកនិងចៀសវាងករណីខ្វះទឹក ពេលរង់ចាំចាក់ថ្នាំកុំយូរពេក អាចបន្ធូរអារម្មណ៍ដោយតន្ត្រី

ខ្សែភាពយន្តឬនិយាយលេង កាលណាទទួលចាក់វ៉ាក់សាំង អង្គុយលើកៅអី។ ម្យ៉ាងទៀត ក្រោយពីចាក់វ៉ាក់សាំង ត្រូវអង្គុយឬដេកសំរាកក្នុងរយៈពេល៣០នាទី ដើម្បីជៀសវាងធ្លាក់ចុះនាំឱ្យរបួសដោយសារសន្លប់។

ក្នុងករណីកើតសន្លប់ពេលចាក់ម្ជុល ស្នើអ្នកទៅកន្លែងសំរាកៗមួយភ្លែតសិនតាមរបៀបអង្គុយឬដេកអោយរាប ហើយបន្ធូរទឹកចិត្តតែងតឹង ហើយជូនដំណឹងឱ្យគ្រូពេទ្យ(បើនៅសាលារៀនត្រូវជូនដំណឹងឱ្យគ្រូបង្រៀននិងគ្រូពេទ្យ)។ បើសិននៅមានបាតុភូតសន្លប់ ត្រូវតែបញ្ជូនទៅមន្ទីរពេទ្យព្យាបាល។

《សុវត្ថិភាពនិងផលបះពាល់》

វ៉ាក់សាំងបង្ការជម្ងឺគ្រុនផ្តាសាយ ជាវ៉ាក់សាំងអសកម្មផលិតដោយវីរុសងាប់ ដូច្នេះយើងទទួលវ៉ាក់សាំងនេះរួច ក៏មិនកើតជម្ងឺគ្រុនផ្តាសាយ។ ក្រោយពីទទួលចាក់វ៉ាក់សាំង មានលទ្ធភាពបណ្តាលឱ្យចំណែកចាក់ថ្នាំឈឺចាប់ ហើម មនុស្សភាគតិចនឹងមានប្រតិកម្មលើរាងកាយទាំងស្រុង ដូចជាក្តៅខ្លួន ឈឺក្បាល ឈឺសាច់ដុំ ចង្អោរ ស្បែករមាស់ ជ្រីវង់ឬសញ្ញាក្រហមជាដើម តាមធម្មតា ក្រោយពីកើតរោគសញ្ញា១ដល់២ថ្ងៃក៏ជាសះស្បើយហើយ។ ដូចជាថ្នាំផ្សេងទៀត ពិតមែនតែមានករណីភាគតិចតួច តែវ៉ាក់សាំងបង្ការជម្ងឺគ្រុនផ្តាសាយក៏មានលទ្ធភាពបង្កើតផលប៉ះពាល់ធ្ងន់ធ្ងរដែរ ដូចជាកើតប្រតិកម្មភ្លាម រហូតដល់កើតសន្លប់(រោគសញ្ញារួមទាំងពិបាកដកដង្ហើម សម្លេងរអិល ជម្ងឺហឺត ភ្នែកឬហើមបបូរមាត់ រិលមុខ ចង្វាក់បេះដូងលោតលឿន។ល។) ប្រសិនបើជាអកុសល រោគសញ្ញាទាំងនេះនឹងកើតឡើងក្នុងរយៈពេលពីរឬបីនាទីទៅពីរឬបីម៉ោងបន្ទាប់ពីចាក់វ៉ាក់សាំង។ ហើយមានផលប៉ះពាល់ផ្សេងទៀតបានរបាយការណ៍ រួមទាំងរោគសញ្ញាប្រព័ន្ធត្រសៃប្រសាទ(ដូចជា: រលាកប្រសាទដៃ ពិការប្រសាទមុខ កន្ត្រាក់ដោយកំដៅខ្ពស់ ពិការប្រសាទ ស៊ីម៉េទ្រី ដូចជារោគសញ្ញាGuillain-Barréជាដើម) និងរោគសញ្ញានៅប្រព័ន្ធឈាម(ដូចជាThrombocytopeniaបណ្តោះអាសន្ន គឺលើស្បែកមានចំណុចពណ៌ស្វាយឬចំណុចឈាម កាលណាហូរឈាមពិបាកឃាត់ឈាមជាដើម)។ ក្រៅពីវ៉ាក់សាំងបង្ការជម្ងឺផ្តាសាយជ្រូកនៅឆ្នាំ១៩៧៦ វ៉ាក់សាំងបង្ការជម្ងឺគ្រុនផ្តាសាយប្រភេទថ្មី H1N1នៅឆ្នាំ២០០៩ និងវ៉ាក់សាំងបង្ការជម្ងឺផ្តាសាយប្រើនៅរដូវខ្លះ ត្រូវអ្នកវេជ្ជសាស្ត្រខាងជម្ងឺឆ្លងបានស្រាវជ្រាវបញ្ជាក់ថា មានទំនាក់ទំនងជាមួយនឹងរោគសញ្ញាGuillain-Barré

ករណីផ្សេងទៀតគ្មានស្ថិតិអាចបញ្ជាក់ថាមានទំនាក់ទំនងជាមួយនឹងការចាក់វ៉ាក់សាំងបង្ការជម្ងឺផ្តាសាយទេ។ ម្យ៉ាងទៀតលទ្ធផលស្រាវជ្រាវធរមាននិងរបាយការណ៍អង្គការសុខភាពពិភពលោកបានបង្ហាញថា ស្ត្រីមានផ្ទៃពោះដែលទទួលវ៉ាក់សាំងអសកម្មក្នុងអំឡុងពេលមានផ្ទៃពោះមិនដែលបន្ថែមគ្រោះថ្នាក់ដល់ការមានផ្ទៃពោះនិងទារកទេ។

តាមការស្រាវជ្រាវបច្ចុប្បន្ននេះបានរកឃើញថា ការចាក់វ៉ាក់សាំងការពារជំងឺគ្រុនផ្តាសាយដែលដំណើតការផលិតមានអំប្រិយ៉ុងពងមាន់ សម្រាប់អ្នកដែលមានអាឡែហ្ស៊ីស៊ុតនឹងមិនប៉ះពាល់ដល់អត្រាកើតប្រតិកម្មអាលែហ្សីទេ សង្គមអន្តរជាតិបានលើកឡើងសំណើថា អ្នកមានអាឡែស៊ីស៊ុតនឹងពងមាន់អាចទទួលបានវ៉ាក់សាំងផ្តាសាយដោយទំនុកទុកចិត្ត។

វ៉ាក់សាំងបង្ការជម្ងឺគ្រុនផ្តាសាយដែលបានទិញនៅឆ្នាំនេះសុទ្ធតែគ្មានធាតុ Thiomersalate ទេ។

**មជ្ឈមណ្ឌលសុខភាព យកចិត្តទុកដាក់ចំពោះលោកអ្នក**

---

**【លិខិតស្ម័គ្រចិត្តទទួលចាក់វ៉ាក់សាំងបង្ការជម្ងឺគ្រុនផ្តាសាយ】**

ខ្ញុំបានអានហើយយល់ដឹងព័ត៌មានអំពីវ៉ាក់សាំងបង្ការជម្ងឺគ្រុនផ្តាសាយរួចហើយបញ្ជាក់ថាកូនរបស់ខ្ញុំគ្មានតំណមនៅពេលទទួលវ៉ាក់សាំងដូចខាងលើនេះ ហើយសម្រេចថា កូនរបស់ខ្ញុំ លេខ__________ថ្នាក់__________ឆ្នាំ__________ (ថ្ងៃកំណើតថ្ងៃ____ខែ______ឆ្នាំ__________ ភេទ៖ □ប្រុស □ស្រី)

**□ យល់ព្រមទទួលចាក់វ៉ាក់សាំង**

**□ មិនយល់ព្រមទទួលចាក់វ៉ាក់សាំង មូលហេតុ ៖______________________**

**ហត្ថលេខារបស់ឪពុកម្តាយ ៖____________**

**（សូមចុះហត្ថលេខាដោយនាមត្រកូលនិងនាមខ្លួនជាភាសាចិន）កាលបរិច្ឆេទ ៖ ថ្ងៃ____ខែ_____ឆ្នាំ__________**

ពត៌មានអំពីការចាក់វ៉ាក់សាំងបង្ការជម្ងឺគ្រុនផ្តាសារនិងវិធានការបង្ការពាក់ព័ន្ធ សូមមើលវេបសាយរបស់នាយកដ្ឋានគ្រប់គ្រងជម្ងឺ(http://www.cdc.gov.tw) ឬហៅទូរស័ព្ទពិសេសលេខ1922ដែលឥតបង់ថ្លៃសំរាប់ប្រជាជនរាយការណ៍ជម្ងឺនិងពិគ្រោះយោបល់។